ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ម៉ៃ ឃើយ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៣
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "**វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី**" "**SITC INTERNATIONAL INSTITUTE**" ហៅកាត់ជាភាសាខ្មែរ "វ.អ.អ.អ.ធ.ស"

និង ហៅជាភាសាអង់គ្លេស "S.I.I." ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និង មានទីតាំងគោលស្ថិតនៅ អាគារលេខ ៣១៥ ផ្លូវ ហ្សាលដឺហ្គូល សង្កាត់ អូរឬស្សីទី ២ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី ធ្វើការបណ្តុះបណ្តាលក្រិតបរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ក្រេឌីត ជាមធ្យម និងថ្នាក់ម៉ាស្ទ័រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៥៦ ក្រេឌីត ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី មានមហាវិទ្យាល័យ :

១- មហាវិទ្យាល័យ គ្រប់គ្រងពាណិជ្ជកម្ម :

- ថ្នាក់បរិញ្ញាប័ត្រ មានឯកទេស គណនេយ្យ គ្រប់គ្រង ពាណិជ្ជកម្មអន្តរជាតិ ទីផ្សារ ហិរញ្ញវត្ថុនិងធនាគារ និង សណ្ឋាគារនិងទេសចរណ៍ ។
- ថ្នាក់ម៉ាស្ទ័រគ្រប់គ្រងពាណិជ្ជកម្ម មានឯកទេស គ្រប់គ្រងហិរញ្ញវត្ថុនិងធនាគារ និង គ្រប់គ្រង ។

២- មហាវិទ្យាល័យភាសាអង់គ្លេស :

- ថ្នាក់បរិញ្ញាប័ត្រ មានឯកទេស ការអប់រំភាសាអង់គ្លេស ។

ទៅអនាគតវិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ សាខា ឯកទេស ក្រិត ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេចលើគោលនយោបាយ ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្រ: បេក្ខជនត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺសញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនត្រូវមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី ត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់ អំពីការជ្រើសរើសនិស្សិតអោយចូលរៀន នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** នាយក វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី មានភារកិច្ច :

- ទទួលខុសត្រូវ នៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ។
- ជ្រើសរើសសិស្ស-និស្សិតអោយចូលរៀន ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និង បុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលង និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និងសេចក្តីណែនាំ របស់ក្រសួងអប់រំ យុវជននិងកីឡា និង រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។

- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់ កម្មវិធីសិក្សា របស់វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្របរិញ្ញា ឬ សញ្ញាប័ត្រម៉ាស្ទ័រ តាមឯកទេស និង តាមកំរិត ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយ វិទ្យាស្ថាន អន្តរជាតិ អេស អាយ ធី ស៊ី ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អគ្គនាយកដ្ឋាន អង្គភាព-ពាក់ព័ន្ធ និង វិទ្យាស្ថានអន្តរជាតិ អេស អាយ ធី ស៊ី មានភារកិច្ចរៀងៗខ្លួន ដើម្បីអនុវត្ត និងប្រតិបត្តិតាម អនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

"<u>ដើម្បីមុខការ</u>"

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ